ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១៣ លេខ ៤ តុលា - ធ្នូ ឆ្នាំ២០០៩ តម្លៃ ១.៥០០៛

# ការបង្កើនប្រសិទ្ធភាព នៃការផ្តល់សេវាផលិតកម្ម នៅជនបទកម្ពុជា*


ទីស្នាក់ការសមាគមកសិករផលិតគ្រាប់ពូជស្រូវ ក្នុងស្រុកសូត្រនិគម. ខេត្តសៀមរាប

## សេចក្តីផ្តើម

ប្រព័ន្ធផ្តល់សេវាផលិតកម្មនៅជនបទ (Rural Productive Service Delivery Systems: RPSDS) នេះ ពួកអ្នកផ្គត់ផ្គង់បានរៀបចំឡើង ក្នុងគោលគំនិតធានាឱ្យផលិតផល និងសេវានានាត្រូវបានផលិត កែច្នៃ និងបញ្ចូលទីផ្សារ ដើម្បីឱ្យបានទៅដល់ដៃអតិថិជននៅទីបញ្ចប់ ។ គំនិតនេះពួកអ្នកផ្គត់ផ្គង់សេវា ទាំងខាងរដ្ឋាភិបាល វិស័យឯកជន និងសង្គមស៊ីវិលបានផ្តួចផ្តើមឡើងជាយូរឆ្នាំមកហើយ ។តាំងពីកម្ពុជាបានអនុវត្តរបបសេដ្ឋកិច្ចទីផ្សារនៅឆ្នាំ១៩៩៣មក មានវិស័យជាច្រើនបានផ្តល់ជាសេវាផ្សេងៗ ប៉ុន្តែគេនៅមានការយល់ដឹងតិចតួចនៅឡើយពីប្រសិទ្ធភាពនៃ RPSDS នៅកម្ពុជា ។ ដូច្នេះត្រូវពិនិត្យមើលឡើងវិញពីប្រព័ន្ធទាំងនេះ ជាពិសេសបញ្ហានានាដែលរាំងស្ទះដល់ការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព ។

## ការសិក្សានេះគោលដៅជាសំខាន់:

- ធ្វើការវាយតម្លៃពីផលប៉ះពាល់ និងចីរភាពនៃ RPSDS ដែលបានជ្រើសរើសមួយចំនួន និងដែលបច្ចុប្បន្នកំពុងដំណើរការនៅកម្ពុជា ។
- កំណត់ពីឧបសគ្គ និងបញ្ហាប្រឈមផ្សេងៗ ដែលរាំងស្ទះដល់ ប្រសិទ្ធភាពនៃ RPSDS ។
- ផ្តល់ជាអនុសាសន៍មួយចំនួនសំដៅកែលំអ RPSDS និងដាក់បញ្ចូលប្រព័ន្ធនេះទៅក្នុងកម្មវិធី ផែនការ យុទ្ធសាស្ត្រ និងនយោបាយតាមវិស័យ/ថ្នាក់ជាតិ ។

## ក្របខ័ណ្ឌ និងវិធីសាស្ត្រស្រាវជ្រាវ

ការសិក្សានេះវាយតម្លៃពីផលប៉ះពាល់ ចីរភាព ឧបសគ្គ បញ្ហាប្រឈម ចំណាប់អារម្មណ៍របស់កសិករពីយុទ្ធសាស្ត្រ និងគោលនយោបាយដែលរដ្ឋាភិបាលដាក់ចេញលើការងារកសិកម្ម ឥរិយាបថ និងការអនុវត្តជាក់ស្តែងរបស់កសិករក្នុងការអភិវឌ្ឍអាជីវកម្ម ដំណើរការទីផ្សារកសិកម្ម និងការលើកទឹកចិត្តខាងទីផ្សារនៅក្នុងខេត្តចំនួនបី គឺខេត្តតាកែវ កំពង់ស្ពឺ និងសៀមរាប

## មាតិកា

ការបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាផលិតកម្ម នៅជនបទកម្ពុជា ........................................ ១
អ្នកលក់ដូរនៅផ្សារក្នុងទីរួមខេត្តកំពង់ចាមប្រកបមុខរបរលក់ដូរ ដើម្បីចិញ្ចឹមជីវិតក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ........................ ៦
អភិបាលកិច្ចមូលដ្ឋានលើធនធានទូពព្រៃ៖ ករណីសិក្សាពីធារាសាស្ត្រនៅកម្ពុជា ........................ ១២
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស........................ ១៦
— ស្ថានភាពក្នុងប្រទេស........................ ១៨
ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI ........................ ២៤

* អត្ថបទនេះ បានតាក់តែងឡើងដោយលោក នេត នាថ (អ្នកស្រាវជ្រាវ និងអតីតអ្នកសម្របសម្រួលកម្មវិធីអភិវឌ្ឍន៍សង្គម) លោក គឹម សុធន (អ្នកស្រាវជ្រាវ) និង បណ្ឌិត ថេង វុទ្ធី (អ្នកសម្របសម្រួលកម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ) នៅវិទ្យាស្ថាន CDRI និងដោយមានការចូលរួមចំណែកពីសំណាក់ លោក ឈឹម ឈន់ (ជំនួយការស្រាវជ្រាវក្នុងកម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ) និង អ្នកស្រី ប៉ុន ដូរីណា (អ្នកសម្របសម្រួលការចុះសិក្សាដល់កន្លែង) នៅ CDRI ។ អត្ថបទនេះ ផ្អែកលើគំរោងមួយសិក្សាពីប្រធានបទដូចគ្នា និងទទួលមូលនិធិពី IFAD ដែល CDRI សូមអរគុណយ៉ាងជ្រាលជ្រៅ ។

ដែលបច្ចុប្បន្នមានអ្នកផ្តល់សេវាចំនួន ៦ក្រុម កំពុងដំណើរការគឺ ១) សេវាចំរុះផ្តល់ដោយក្រុមហ៊ុន AQIP ដែលផ្តោតជាចំបងលើការផ្គត់ផ្គង់គ្រាប់ពូជ និងការគ្រប់គ្រងការខាតបង់នៅក្រោយពេលប្រមូលផល ២) ការផ្សព្វផ្សាយបច្ចេកទេសកសិកម្មចំរុះ សេវាខាងហិរញ្ញវត្ថុ និងទីផ្សារ ផ្តល់ដោយអង្គការ CEDAC និង ៣) សេវាផ្តល់ដោយគំរោង ECOSORN លើផ្នែកផលិតកម្មកសិកម្មចំរុះ ហិរញ្ញវត្ថុ ទីផ្សារ និងសេវាខាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ៤) សេវាខាងផ្សព្វផ្សាយបច្ចេកទេស និងម៉ាឃីតទីង ផ្តល់ដោយអង្គការស្រែខ្មែរ ៥) សេវាផ្តល់ព័ត៌មានទីផ្សារកសិកម្ម ផ្តល់ដោយគំរោង CAMIP និង ៦) សេវាហិរញ្ញវត្ថុផ្តល់ដោយធនាគារ ACLEDA ។

ការសិក្សានេះបានប្រើវិធីសាស្ត្រសិក្សាឯកសារនៅការិយាល័យ និងការចុះអង្កេតដល់កន្លែង ។ ការសិក្សាឯកសារនៅការិយាល័យមានការពិនិត្យឡើងវិញ នូវព័ត៌មានមានស្រាប់ស្តីពីគោលនយោបាយយុទ្ធសាស្ត្រ និងកម្មវិធីផ្សេងៗរបស់រដ្ឋាភិបាល រីឯការចុះអង្កេតដល់កន្លែង បានប្រើបច្ចេកទេស ៣ យ៉ាង ដើម្បីប្រមូលយកព័ត៌មានដំបូង គឺមានការសង្កេតដោយផ្ទាល់តាមរយៈទស្សនកិច្ចដល់កន្លែង បទសម្ភាសស៊ីជម្រៅ និងការពិភាក្សាតាមក្រុមស្នូល(FGD) ។ការសម្ភាសបានធ្វើឡើង៦លើកជាមួយអ្នកផ្តល់សម្ភាសន៍ចំនួន ៣២នាក់ មកពីក្រុមអ្នកផ្តល់សេវាទាំង ៦ក្រុម ហើយ FGD បានធ្វើ ១១លើក នៅក្នុង ១០ភូមិ ។ ក្នុង FGD នីមួយៗ មានអ្នកចូលរួម ១០នាក់ជាមធ្យម ។ ជាលក្ខណៈបច្ចេកទេសវិញ ការសិក្សាបានប្រើវិធីសាស្ត្រខ្សែចង្វាក់កំណត់តម្លៃ វិធីសាស្ត្រខ្សែចង្វាក់ផ្គត់ផ្គង់ និងវិធីសាស្ត្រប្រព័ន្ធកសិកម្ម ដើម្បីវាយតម្លៃ និងវិភាគពីបញ្ហាផ្សេងៗ ។ អត្ថបទនេះបានរៀបចំឡើងតាមលំដាប់លំដោយដូចតទៅ: ការពិនិត្យត្រួសៗ ពីអ្នកផ្តល់សេវា ផលប៉ះពាល់ និងចីរភាព ឧបសគ្គ និងបញ្ហាប្រឈម ចំណាប់អារម្មណ៍របស់កសិករ សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ។

**ដែនកំណត់:** អ្នកផ្តល់សេវាដែលបានជ្រើសយក និង FGD គឺជាគំរូតាងមួយតូចណាស់នៅក្នុងតែ ៣ខេត្ត ប៉ុណ្ណោះ ហើយសេវាដូចគ្នាដែលអ្នកផ្តល់ដូចគ្នាបានផ្តល់ក្នុងខេត្តផ្សេងៗទៀត គឺមិនអាចដាក់បញ្ចូលបានទេ ដោយសារកំហិតខាងធនធាន និងពេលវេលា ។ ក្នុងរយៈពេលសិក្សាសរុបចំនួន ៤៥ថ្ងៃ នៅខែមករា-មីនា ២០០៩ យើងអាចលៃចែកពេលវេលាបានត្រឹមតែ ១៤ថ្ងៃប៉ុណ្ណោះ សំរាប់ការចុះអង្កេតដល់កន្លែង ។ ដូច្នេះលទ្ធផលរកឃើញ ការពិភាក្សា និងសេចក្តីសន្និដ្ឋាននៃការសិក្សានេះ គឺផ្អែកលើអ្នកផ្តល់សេវា និងបណ្តាខេត្តដែលបានជ្រើសយកមកសិក្សា ដូច្នេះអាចមិនគ្រប់គ្រាន់សំរាប់ធ្វើការសន្និដ្ឋានជាទូទៅទេ ។

## លទ្ធផលរកឃើញ

### អ្នកផ្តល់សេវា

*ការពិនិត្យត្រួសៗ*

អង្គការស្រែខ្មែរ, ECOSORN, CEDAC និង AQIP មានផ្តល់សេវាចំរុះជាច្រើន ប៉ុន្តែកំរិតចំរុះ និងលក្ខណៈសំគាល់នៃសេវាទាំងនោះ វាប្រែប្រួលខុសៗគ្នា ។ ECOSORN មានសេវាចំរុះ ៥យ៉ាង អង្គការស្រែខ្មែរ មានសេវាចំរុះ ៣យ៉ាង និង AQIP មានតែ ២យ៉ាង ប៉ុណ្ណោះ ។ អង្គការស្រែខ្មែរ, ECOSORN និង CEDAC ជាអង្គភាពមិនស្វែងរកចំណេញ រីឯ AQIP ជាអង្គភាពស្វែងរកចំណេញ ។ ការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ដែលរួមមានប្រព័ន្ធប្រពលវប្បកម្មស្រូវ (SRI) ប្រព័ន្ធព័ត៌មានទីផ្សារ ការបង្កើតសមាគមផលិតករ និងការបណ្តុះបណ្តាលបច្ចេសទេសគ្រប់គ្រងសាច់ប្រាក់ ត្រូវបានផ្តល់ទៅឱ្យកសិករគំរូដោយ ECOSORN ចំណែកឯអង្គការ CEDAC និងស្រែខ្មែរវិញ មិនមានបញ្ចូលនូវប្រព័ន្ធព័ត៌មានទីផ្សារ ឬការបណ្តុះបណ្តាលបច្ចេកទេសគ្រប់គ្រងសាច់ប្រាក់ទេ ប៉ុន្តែអង្គការទាំងនេះជួយកសិករក្នុងការបង្កើតជាក្រុមសន្សំប្រាក់ និងផ្តល់ការបណ្តុះបណ្តាលពីគោលគំនិតសំខាន់ៗ នៃតំលៃបន្ថែមដូចជា ការជ្រើសរើសមុខដំណាំមានតំលៃខ្ពស់ទៅតាមរដូវកាលជាក់លាក់ជាដើម ។

CEDAC មានបញ្ចូលការបណ្តុះបណ្តាលពីការបង្កើតសមាគមផលិតករនៅក្នុងការផ្តល់សេវារបស់ខ្លួន ប៉ុន្តែអង្គការស្រែខ្មែរមិនមានសេវានេះទេ ។ ក្រុមហ៊ុន AQIP បានបង្កើតជាសមាគមផលិតករមួយ ដើម្បីផ្គត់ផ្គង់ គ្រាប់ពូជទៅក្រុមហ៊ុន ។ ECOSORN ខុសប្លែកពីអង្គការ CEDAC ស្រែខ្មែរ និង AQIP គឺមិនមានផ្តល់សេវាដោយផ្ទាល់ ដល់កសិករឡើយ ប៉ុន្តែបានចុះកិច្ចសន្យាម៉ៅការបន្តទៅឱ្យអ្នកផ្តល់សេវា មានជំនាញឯកទេស ដើម្បីឱ្យគេផ្តល់សេវាដ៏ជាក់លាក់ផ្សេងៗទៅដល់កសិករគំរូ និងតំបន់នៅក្នុងគំរោង ។ ECOSORN ធ្វើដូច្នេះ ព្រោះមិនមានបុគ្គលិក និងសមត្ថភាពគ្រប់គ្រាន់ដើម្បីផ្តល់សេវាដោយផ្ទាល់ ។ ស្រដៀងគ្នានេះដែរ ដោយសារកង្វះដី និងបុគ្គលិកក្រុមហ៊ុន AQIP បានសម្របសម្រួលជាមួយសមាគមផលិតកររបស់ខ្លួន តាមរយៈការចុះកិច្ចសន្យាជាមួយសមាគម លើការផ្គត់ផ្គង់គ្រាប់ពូជក្នុងតម្លៃបានព្រមព្រៀងគ្នា ។ ជាការតបស្នង AQIP យល់ព្រមផ្តល់ឧបត្ថម្ភធនឱ្យសមាគមតាមរយៈកំចីមិនគិតការប្រាក់សំរាប់ជី និងគ្រាប់ពូជ ។

អង្គការស្រែខ្មែរ និង CEDAC ផ្តល់សេវាក្នុងទំរង់ត្រឹមជាការបណ្តុះបណ្តាលប៉ុណ្ណោះ គឺមិនមានប្រព័ន្ធសម្របសម្រួលជាក់លាក់ឡើយ ។ ACLEDA ជាធនាគារពាណិជ្ជ ដែលផ្តល់តែសេវា ហិរញ្ញវត្ថុ រីឯ CAMIP ដែលជាគំរោងផ្តល់មូលនិធិ ដោយអង្គការ CIDA និងរដ្ឋាភិបាលកម្ពុជានោះ មានផ្តល់ត្រឹមព័ត៌មាន ពីទីផ្សារកសិកម្មប៉ុណ្ណោះ ។ ACLEDA បានបង្កើតតំលៃបន្ថែមសំរាប់អង្គភាពខ្លួនផ្ទាល់ និងបានបង្កើតគោលនយោបាយបទបញ្ជា និងប្រព័ន្ធគ្រប់គ្រងរបស់ខ្លួនផ្ទាល់ ដើម្បីសម្របសម្រួលការផ្តល់សេវា ។ CAMIP ជាគំរោងសាធារណៈ មិនស្វែងរកចំណេញមួយដែលត្រូវដំណើរការ ៤ឆ្នាំ (២០០៦-២០០៩) ហើយមិនមានទាក់ទង ឬក៏បង្កើតនូវប្រព័ន្ធខ្សែចង្វាក់កំណត់តម្លៃអ្វីឡើយ ។ មុខងារចំបងរបស់ CAMIP គឺបញ្ជូនព័ត៌មានទីផ្សារកសិកម្មទៅឱ្យភាគីដែលចាប់អារម្មណ៍ ។ ការសម្របសម្រួលរវាង CAMIP និងអ្នកលក់ដុំ ដើម្បីទទួលបានព័ត៌មានពីថ្លៃលក់ដុំ និងអត្ថប្រយោជន៍ទៅវិញទៅមក គឺឈរលើមូលដ្ឋានស្ម័គ្រចិត្តជាសំខាន់ ។

### *ផលប៉ះពាល់ និងចីរភាព*

កសិករភាគច្រើន បានជ្រើសប្រើគ្រាប់ពូជដែលផ្តល់ផលល្អ ប៉ុន្តែការទទួលយកប្រព័ន្ធប្រពលវប្បកម្មស្រូវ (SRI) វាប្រែប្រួលខុសគ្នាពីកន្លែងមួយទៅកន្លែងមួយ ។ កសិករទាំងអស់ដែលមានកិច្ចព្រមព្រៀងជាមួយ AQIP ទទួលយក SRI ហើយ ២៥% នៃកសិករគំរូរបស់ CEDAC ទទួលយកប្រព័ន្ធនេះដែរ រីឯកសិករគំរូមួយភាគធំរបស់ ECOSORN និងអង្គការស្រែខ្មែរ ទំនងជាមិនទទួលយកប្រព័ន្ធនេះទេ ។ កសិករភាគច្រើនមិនចង់ទទួលយក SRI ពីព្រោះត្រូវប្រើពលកម្មច្រើន ។ កសិកររបស់ AQIP បានទទួលយក SRI ព្រោះត្រូវគោរពតាមកិច្ចសន្យា ។ស្រដៀងគ្នានេះដែរ ការជ្រើសប្រើវិធានការចំរុះថែទាំដំណាំ (IPM) ដោយកសិករគំរូក៏ប្រែប្រួលខុសគ្នា ព្រោះកសិករខ្លះយល់ថា ថ្នាំគីមីសំលាប់សត្វល្អិតវាមានប្រសិទ្ធភាពជាងថ្នាំសំលាប់សត្វល្អិតតាមបែបធម្មជាតិ ។ ទោះយ៉ាងនេះក្តី កសិករភាគច្រើនរាយការណ៍ថា គ្រាប់ពូជគុណភាពខ្ពស់ ប្រព័ន្ធ SRI វិធានការចំរុះថែទាំដំណាំ និងការប្រើជីកំប៉ុស បានបង្កើនផលិតភាពនិងតំលៃបន្ថែម ។កសិករជាប់កិច្ចសន្យាជាមួយ AQIP បានផ្លាស់ប្តូរពីផលិតកម្មស្រូវសំរាប់មួយរស់ ទៅជាផលិតកម្មស្រូវសំរាប់ពាណិជ្ជកម្ម ។ កសិករនានា បានយល់ដឹងកាន់តែប្រសើរពីគោលការណ៍អាជីវកម្មស្រូវពូជ ដូចជាតំរូវការរបស់អ្នកប្រើប្រាស់លើគ្រាប់ពូជគុណភាពខ្ពស់ជាដើម ។ ធនាគារ ACLEDA បានបង្កើនការផ្តល់កំចីក្នុងវិស័យកសិកម្មទាំងអស់ ពី ១១% នៃការផ្តល់កំចីសរុបនៅឆ្នាំ២០០៧ ដល់ ១៤% នៅឆ្នាំ២០០៨ (៥៤% នៃទឹកប្រាក់កំចីសរុប ខាងកសិកម្ម គឺសំរាប់ផលិតកម្មដំណាំ) ។ ដោយសារការផ្តល់កំចីឱ្យនេះ (អាចមានកត្តារួមចំណែកក្រៅពីនេះទៀត) សហគ្រាសធុនតូច និងមធ្យម អាចធ្វើវិនិយោគជាម៉ាស៊ីនបោកស្រូវ ម៉ាស៊ីនបូមទឹក សំរាប់ដាំបន្លែ និងម៉ាស៊ីនកិនស្រូវ ។ល។ ដែលជួយសំរួលដល់ការទទួលយកបច្ចេកវិទ្យា និងគំនិតច្នៃប្រឌិតថ្មីៗ ។ គេមិនដឹងច្បាស់ទេថា តើសេវាព័ត៌មានទីផ្សារកសិកម្មដែល CAMIP ផ្តល់ឱ្យក្នុងរយៈពេល ៤ឆ្នាំ កន្លងទៅនេះ បានចូលរួមចំណែកប៉ុណ្ណា ក្នុងការលើកស្ទួយសហគ្រាសកសិកម្ម ពីព្រោះកសិករ និងផលិតករភាគច្រើនបានរាយការណ៍ថា ព័ត៌មានផ្តល់ដោយសេវានោះ ច្រើនតែចាស់ហួសពេល ហើយការបណ្តុះបណ្តាលផ្តល់ដោយសាលាម៉ាឃីទីងសំរាប់កសិករ ក៏មិនសូវមានប្រយោជន៍ដែរ (FGD ថ្ងៃទី ២-៤ កុម្ភៈ ២០០៩) ។

ចីរភាពសេវាកម្ម ផ្អែកលើលក្ខណៈបែបបទ និងវិធីសាស្ត្រនៃការផ្តល់សេវា ។ សេវាចំរុះរបស់ AQIP ទំនងជានឹងបន្តទៅមុខ ពីព្រោះគំរោងនេះអាចរស់រានបានខាងហិរញ្ញវត្ថុ ហើយពួកកសិករជាប់កិច្ចសន្យាបានទទួលផលចំណេញជាកំណើនប្រាក់ចំណូល និងចំណេះដឹង ។ ប៉ុន្តែកំរិតដែលកសិករទទួលយកបច្ចេកវិទ្យា និងសេវារបស់ អង្គការស្រែខ្មែរ ECOSORN និងអាចរបស់ CEDAC និង CAMIP ផងដែរ គឺមិនទាន់ឡើងដល់កំរិតមួយ ដែលអាចធានាថា កសិករគំរូនឹងបន្តប្រើប្រាស់នូវបច្ចេកវិទ្យាទាំងនោះឡើយ ។ កសិករក្រីក្រ ដែលរកមួយថ្ងៃហូបមួយថ្ងៃ ត្រូវការជំនួយបច្ចេកទេស និងហិរញ្ញវត្ថុឱ្យបានច្រើន និងមាន រយៈពេលវែងជាងនេះទៀត ។ ទោះបីជា ECOSORN និងអង្គការស្រែខ្មែរ បានដាក់បញ្ចូលបុគ្គលិកផ្សព្វផ្សាយបច្ចេកទេសមកពីមន្ទីរកសិកម្មខេត្ត និងបានបណ្តុះបណ្តាល អ្នកបណ្តុះបណ្តាលដើម្បីឱ្យពួកគេបន្តផ្តល់សេវា ក្រោយពេលអង្គការបញ្ចប់ការងារក្នុងប៉ុន្មានឆ្នាំខាងមុខក្តី ក៏បុគ្គលិក និងអ្នកបណ្តុះបណ្តាលទាំងនោះ មិនទំនងជានឹងបន្តផ្តល់សេវាឡើយ ព្រោះមិនទាន់ឃើញមានបង្កើតគ្រឿងលើកទឹកចិត្តជាក់លាក់ណាមួយនៅឡើយ (Danish Agricultural Advisory Service ២០០៨ និង FGDs កាលពីថ្ងៃទី ៥ កុម្ភៈ ២០០៩) ។ ធនាគារ ACLEDA ទំនងជាបន្តផ្តល់សេវាហិរញ្ញវត្ថុចំពោះវិស័យកសិកម្ម បើសិនជាមានចីរភាពខាងហិរញ្ញវត្ថុ ។ ធនាគារនេះ បានផ្តល់ហិរញ្ញប្បទានដល់វិស័យកសិកម្មអស់រយៈពេលជិត ២ទសវត្សរ៍ មកហើយ ។ សេវាផ្តល់ព័ត៌មានទីផ្សារកសិកម្ម ទំនងជាមិនអាចបន្តផ្តល់ព័ត៌មានប្រកបដោយគុណភាពទៀតឡើយ នៅពេលគំរោង CAMIP ត្រូវបញ្ឈប់ក្នុងឆ្នាំ២០០៩ ពីព្រោះការិយាល័យទីផ្សារកសិកម្ម (AMO) ខ្វះខាតធនធានសំរាប់បន្តសេវានេះ ។

### *ឧបសគ្គ និងបញ្ហាប្រឈម*

កង្វះមូលធន កង្វះបុគ្គលិកមានសមត្ថភាពគ្រប់គ្រាន់ ការផ្លាស់ប្តូរបុគ្គលិកមានអត្រាខ្ពស់ កសិករមានកំរិតអប់រំទាប ភាពក្រីក្រ កង្វះទឹកនៅរដូវប្រាំង ហេដ្ឋារចនាសម្ព័ន្ធអន់ខ្សោយ (ផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ និងគ្រឿងសម្របសម្រួលទីផ្សារ) កង្វះបច្ចេកទេស និងការផ្សព្វផ្សាយបច្ចេកទេសកសិអាជីវកម្មសំរាប់ជួយទ្រទ្រង់មានមិនគ្រប់គ្រាន់ និងកង្វះការចុះបញ្ជីដីធ្លី គឺជាឧបសគ្គ និងបញ្ហាប្រឈមជាទូទៅ ដែលរារាំងដល់ពួកអ្នកផ្តល់សេវា និងការលើកស្ទួយសហគ្រាសកសិកម្ម ។ ក្រៅពីបញ្ហាខាងលើ ការលំបាកក្នុងការស្វែងរកអ្នកម៉ៅការដែលមានសមត្ថភាព និងការលំបាកក្នុងការគ្រប់គ្រង និងសម្របសម្រួលជាមួយអ្នកម៉ៅការ បានធ្វើឱ្យ ECOSORN ត្រូវពន្យារពេលអនុវត្តគំរោងនៅក្នុងភូមិជាច្រើនខែ ។ អង្គការស្រែខ្មែរ CEDAC និង CAMIP ខ្វះខាតបុគ្គលិកមានសមត្ថភាពល្អ និងមានជំនាញឯកទេសក្នុងការអភិវឌ្ឍអាជីវកម្ម ហើយក៏មិនអាចជួយដល់កសិករ និងសមាគមផលិតករក្នុងការអភិវឌ្ឍអាជីវកម្មបាន ។ ដោយសារកង្វះបុគ្គលិក និងសមត្ថភាពមានកំរិតខាងការអភិវឌ្ឍអាជីវកម្ម សាលាម៉ាឃីទីងសំរាប់កសិករ ដែលដំណើរការដោយ CAMIP មិនមានភាពទាក់ទាញចំពោះកសិករ និងពាណិជ្ជករឡើយ ។

ការរារែករបស់កសិករក្នុងការទទួលយកប្រព័ន្ធ SRI និងកង្វះការផ្គត់ផ្គង់ គឺជាបញ្ហាប្រឈមទូទៅចំពោះអ្នកផ្តល់សេវាគ្រប់ៗគ្នា ។ កង្វះលទ្ធភាពក្នុងការផលិតគ្រាប់ពូជ និងផ្តល់ហិរញ្ញប្បទានដល់កសិករជាប់កិច្ចសន្យា កំពុងចោទបញ្ហាដល់ខ្សែចង្វាក់កំណត់តំលៃរបស់ AQIP ។ កង្វះបុគ្គលិកជំនាញខាងគ្រប់គ្រងអាជីវកម្ម សំរាប់ជួយជ្រោមជ្រែងដល់ហាងលក់ផលិតផលសិរីរាង្គរបស់សហគមន៍ និងសមាគមផលិតករ កំពុងចោទបញ្ហាថែមទៀតដល់ CEDAC ។ សព្វថ្ងៃពួកអតិថិជន ក៏មិនទាន់ពេញចិត្តបង់ថ្លៃខ្ពស់ជាងសំរាប់ផលិតផលសិរីរាង្គនៅឡើយ (FGDs ថ្ងៃទី ២-៤ កុម្ភៈ និងសម្ភាសន៍ ថ្ងៃទី ១០ កុម្ភៈ ២០០៩) ។ បញ្ហានេះបានរាំងស្ទះដល់ការជំរុញផលិតផលសិរីរាង្គ ។ភាពលំបាកនឹងទទួលបានសេវាហិរញ្ញវត្ថុ (ការប្រាក់ខ្ពស់)

និងព័ត៌មានទីផ្សារចាស់ហួសពេល នៅតែជាបញ្ហាប្រឈមចំបង សំរាប់ ACLEDA និង CAMIP ហើយវាបន្តគំរាមកំហែងដល់ការជំរុញសហគ្រាសកសិកម្ម ។ លើសពីនេះទៀត ដោយហេតុថាវិធីសាស្ត្រមួយផ្នែករបស់ CAMIP គឺការផ្សព្វផ្សាយ និងលើកកម្ពស់សមត្ថភាពកសិករ និងពាណិជ្ជករក្នុងមូលដ្ឋាន ដូច្នេះការចូលរួមករិតទាបរបស់ពួកគេ នៅក្នុងកម្មវិធីសាលាម៉ាឃីទីងសំរាប់កសិករ បានរាំងស្ទះដល់ការកសាងសមត្ថភាព និងការប្រើប្រាស់ព័ត៌មាន ។

## ចំណាប់អារម្មណ៍របស់កសិករ

### គោលនយោបាយ និងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលក្នុងវិស័យកសិកម្ម

ក្រុមគ្រួសារភាគច្រើនមានដីតិចតួច ហើយនៅភូមិភាគច្រើនពុំមានទឹកស្រោចស្រពពេញៗមួយឆ្នាំទេ ។ កសិករនៅភូមិទាំងនោះ ត្រូវចំណាយច្រើនលើធាតុចូល (ជី គ្រាប់ពូជ និងសាំងជាដើម) ហើយត្រូវប្រឈមមុខនឹងអត្រាសត្វចិញ្ចឹមឈឺ និងងាប់ក្នុងករិតខ្ពស់ គួបផ្សំនឹងកង្វះការជ្រើសរើសបង្កាត់ពូជសត្វទៀតផង ។ កសិករភាគច្រើនយល់ថា បញ្ហាទាំងនេះជាឧបសគ្គចំបងៗ ដែលរារាំងដល់គោលនយោបាយរបស់រដ្ឋាភិបាល ស្តីពីការធ្វើពិពិធកម្មសន្តិសុខស្បៀង និងការបង្កើនផលិតភាព ។ កសិករភាគច្រើនយល់ឃើញថា បុគ្គលិកដែលមានសមត្ថភាពមិនគ្រប់គ្រាន់ និងសន្ទុះចិត្តខ្សោយ បានចោទជាបញ្ហាចំពោះគោលនយោបាយតាមវិស័យស្តីពីការពង្រឹង និងកែលំអការស្រាវជ្រាវខាងកសិកម្ម និងធ្វើឱ្យទន់ខ្សោយដល់ក្របខ័ណ្ឌអភិវឌ្ឍន៍ស្ថាប័ន និងការបង្កើតច្បាប់សំរាប់ប្រព័ន្ធផ្តល់សេវាផលិតកម្មនៅជនបទ ។ ការទទួលបានព័ត៌មានមិនស្មើគ្នាក្នុងចំណោមកសិករ និងប្រព័ន្ធចែកចាយផលិតផលគ្មានប្រសិទ្ធភាពនៅតាមតំបន់សិក្សាភាគច្រើន បានធ្វើឱ្យកសិករ និងពាណិជ្ជករភាគច្រើននៅតាមមូលដ្ឋានជឿថា គោលនយោបាយស្តីពីច្រកទីផ្សារសំរាប់ផលិតផលកសិកម្មទំនងមិនបានជោគជ័យឡើយ ។ ភាពយឺតយ៉ាវនៃការចុះបញ្ជីដីធ្លី និងកំណើនជម្លោះដីធ្លី ក៏បង្កឧបសគ្គដល់គោលនយោបាយស្តីពីការកាន់កាប់ដី ការអភិវឌ្ឍទីផ្សារដីធ្លី និងការប្រើប្រាស់ដីអំណោយផលដល់អ្នកក្រផងដែរ ។ ជាលទ្ធផល ក្រុមគ្រួសារភាគច្រើនមិនទាន់ទទួលបានប័ណ្ណកម្មសិទ្ធិលើដីធ្លីរបស់ខ្លួនទេដែលធ្វើឱ្យអ្នកក្រីក្រភាគច្រើនមិនអាចទទួលបានឥណទាន ។

### របៀបរបបអនុវត្ត និងឥរិយាបទរបស់កសិករក្នុងការធ្វើអាជីវកម្ម

កសិករភាគច្រើនយល់ថា ដី ទឹក និងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ជាកត្តាសំខាន់បំផុត សំរាប់ការដោះស្រាយស្បៀងអាហារក្នុងគ្រួសារ រីឯហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ប្រព័ន្ធព័ត៌មានទីផ្សារ សេវាគាំទ្រខាងកសិអាជីវកម្ម និងលទ្ធភាពទទួលបានឥណទាន និងបច្ចេកវិទ្យា គឺជាកត្តាសំខាន់បំផុតដើម្បីបង្កើនផលិតកម្មសំរាប់លក់ ។

### គ្រឿងលើកទឹកចិត្តទីផ្សារ

កង្វះការគាំទ្រជាធាតុចូលកសិកម្ម និងការគាំទ្រខាងអាជីវកម្ម ថ្លៃប្រេងខ្ពស់ ថ្លៃជីខ្ពស់ កង្វះការពេញចិត្តពីអតិថិជនលើការបង់ថ្លៃបន្ថែមសំរាប់ផលិតផលសរីរាង្គ តំរូវការទាបនូវផលិតផលកសិកម្មក្នុងស្រុក និងអត្រាការប្រាក់ខ្ពស់នៅតាមធនាគារ និងស្ថាប័នហិរញ្ញវត្ថុខ្នាតតូច (MFIs) គឺជាឧបសគ្គចំបងៗចំពោះកសិករក្នុងការឆ្លើយតបនឹងតម្រូវការទីផ្សារ ។ នៅឆ្នាំ២០០៨ ជីគីមីលក់ថ្លៃ ១៦០.០០០រៀល/បាវ ធៀបនឹង ៦០.០០០រៀល/បាវ កាលពីឆ្នាំ២០០៥ (AMO 2005; AMO 2008) ។ ថ្លៃប្រេងក៏មាននិន្នាការស្រដៀងគ្នានេះ ។ ការគាំទ្រខាងអាជីវកម្ម ក៏មិនមានផ្តល់ឱ្យកសិករដែរ ។ ទើបតែថ្មីៗនេះទេ ដែលគេបានណែនាំបង្ហាញដល់កសិករពីខ្សែចង្វាក់កំណត់តំលៃ និងតំលៃបន្ថែម តាមរយៈការបណ្តុះបណ្តាលនៅតាមភូមិជ្រើសរើសមួយចំនួន ប៉ុន្តែនៅមានភូមិភាគច្រើនណាស់ ដែលមិនទាន់ទទួលបានការណែនាំឬការគាំទ្រតាមរូបភាពនេះ ។ លទ្ធផលរកឃើញក្នុងការសិក្សានេះ (FGD ហាងលក់ផលិតផលសរីរាង្គរបស់សហគមន៍តាមការណែនាំរបស់ CEDAC នៅខេត្តតាកែវ និងការសម្ភាសជាមួយអតិថិជន កាលពីថ្ងៃទី ២-៤ កុម្ភៈ ២០០៩) និងការសិក្សារបស់ក្រុមហ៊ុន Agrifood Consulting International and CamConsult (2006) បានបង្ហាញថា អតិថិជននៅមិនទាន់ពេញចិត្តបង់ថ្លៃបន្ថែមសំរាប់ផលិតផលកសិកម្មសរីរាង្គទេ ។ ថ្លៃប្រេងខ្ពស់ ថ្លៃជីខ្ពស់ និងអវត្តមានការគាំទ្រជាធាតុចូលកសិកម្ម ធ្វើឱ្យកសិករមើលមិនឃើញពីផលចំណេញក្នុងការឆ្លើយតបនឹងតំរូវការទីផ្សារ ។ មានតែកសិករមួយភាគតូច ដែលគេអញ្ជើញឱ្យចូលរួមក្នុងគំរោងសាកល្បងនោះទេ ដែលទទួលបានការគាំទ្រជាធាតុចូល ហើយជំនួយគាំទ្រនេះ គឺសំរាប់តែការងារធ្វើបង្ហាញឱ្យឃើញជាក់ស្តែងប៉ុណ្ណោះ ។

### ដំណើរការនៃទីផ្សារកសិកម្ម

ការត្អូញត្អែរចំបងៗរបស់កសិករភាគច្រើនស្តីពីដំណើរការទីផ្សារ រួមមានពាណិជ្ជករនៅក្នុងភូមិនីមួយៗមានតិចនាក់ពេក (១នាក់ ទៅ ៣នាក់) ពាណិជ្ជករឱ្យថ្លៃទាបជាងថ្លៃផ្សព្វផ្សាយតាមវិទ្យុ ការទទួលបានព័ត៌មានមិនស្មើគ្នាអំពីថ្លៃទំនិញនិងទីផ្សារ ផលិតផលក្នុងស្រុកមិនសូវមានលក្ខណៈប្រកួតប្រជែង និងការឡើងចុះខ្លាំងនៃថ្លៃផលិតផល ។ កសិករភាគច្រើនជឿថាដំណើរការទីផ្សារកសិកម្មបច្ចុប្បន្ន មានលក្ខណៈមិនសូវល្អដោយសារតែព័ត៌មានទទួលបានមិនស្មើគ្នា ។ ភាពមិនស្មើគ្នានេះ បណ្តាលមកពីការដឹកជញ្ជូន និងការទទួលបានព័ត៌មាន មានតំលៃខ្ពស់ពេក ។ Higgins (2009) បានរាយការណ៍ថា ចំណាយដឹកជញ្ជូននៅកម្ពុជាថ្លៃលើសនៅថៃស្មើរដល់ ៣,៧៥ដង[1] ហើយផ្តល់ក្រាលកៅស៊ូនៅកម្ពុជាមាន ៥% ធៀបនឹង ៩៨% នៅថៃ ។ មានតែពាណិជ្ជករ និងអ្នកលក់ដុំមួយចំនួនដែលក្តាប់ព័ត៌មានទីផ្សារបានល្អប៉ុណ្ណោះ ដែលទទួលបានផលចំណេញ ដូច្នេះពួកគេមិនចង់ឱ្យថ្លៃខ្ពស់សមរម្យដល់កសិករឡើយ ។ CAMIP បានធ្វើការផ្សព្វផ្សាយពីថ្លៃទំនិញលើទីផ្សារតាមរយៈវិទ្យុ ទូរស័ព្ទ វែបសាយ និងការបោះពុម្ពផ្សាយផ្សេងៗនៅតាម ១១ ខេត្តក្រុង ដែលមានទាំងខេត្តសៀមរាប និងតាកែវ ប៉ុន្តែព័ត៌មាននេះ នៅតែមិនបានទៅដល់កសិករភាគច្រើន ដោយ

---

១ ១៥ដុល្លារ/តោន ក្នុងចំងាយផ្លូវ ១០០គីឡូម៉ែត្រ នៅកម្ពុជា ធៀបនឹង ៧ដុល្លារ នៅវៀតណាម និង ៤ដុល្លារ នៅថៃ (Higgins, ២០០៩)

សារតែកង្វះចំណាប់អារម្មណ៍ពីសេវា ភាពស្មុគស្មាញខាងបច្ចេកទេស ភាពចាស់ហួសពេលនៃព័ត៌មាន និងកង្វះឧបករណ៍ទទួលព័ត៌មាន ។ ព័ត៌មានចាស់ហួសពេល ពីព្រោះ CAMIP ធ្វើការប្រមូលវារៀងរាល់បីថ្ងៃម្តងប៉ុណ្ណោះ ។ កសិករភាគច្រើននិយាយថា ទីផ្សារប្រហែលនឹងមានដំណើរការប្រសើរឡើង ប្រសិនបើពាណិជ្ជករ និងអ្នកលក់ដុំមានចំនួនកាន់តែច្រើន ហើយការទទួលបានព័ត៌មាន វាមានតំលៃទាបជាងនេះ ។

## សន្និដ្ឋាន

ការសិក្សាលើអ្នកផ្តល់សេវាទាំង ៦ ក្រុម បានបង្ហាញពីបែបបទផ្តល់សេវាពីរប្រភេទ ។ ACLEDA និង CAMIP ផ្តល់សេវាទោល រីឯអង្គការស្រែខ្មែរ ECOSORN, CEDAC និង AQIP ផ្តល់សេវាចំរុះ ។ ផលប៉ះពាល់ និងចីរភាពនៃសេវាទាំងនោះ ផ្អែកលើលក្ខណៈផ្ទាល់ និងវិធីសាស្ត្រផ្គត់ផ្គង់របស់អ្នកផ្គត់ផ្គង់សេវា ។ ឧបសគ្គ និងបញ្ហាប្រឈមចំបងៗ ចំពោះយុទ្ធសាស្ត្រ និងគោលនយោបាយខាងកសិកម្មរបស់រដ្ឋាភិបាល រួមមានកង្វះខាត ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ បច្ចេកទេស/ការផ្សព្វផ្សាយបច្ចេកទេស ព័ត៌មានទីផ្សារ ការគាំទ្រជាសេវាកសិអាជីវកម្ម ដីដាំដុះ ទឹក សេវាហិរញ្ញវត្ថុ ការគាំទ្រជាធាតុចូលកសិកម្ម ការអប់រំ គួបផ្សំនឹងភាពក្រីក្រខ្លាំងនៃគ្រួសារកសិករ ថ្លៃប្រេងខ្ពស់ និងថ្លៃជីខ្ពស់ ។ បញ្ហាទាំងនោះបានរាំងស្ទះផងដែរ ដល់សហគ្រាសកសិកម្ម ការឆ្លើយតបរបស់កសិករចំពោះគ្រឿងលើកទឹកចិត្តទីផ្សារ និងចំណាប់អារម្មណ៍របស់កសិករ អំពីដំណើរការទីផ្សារកសិកម្ម ហើយក៏ក្លាយជាឧបសគ្គចំពោះការផ្តល់សេវាផលិតកម្មនៅជនបទប្រកបដោយប្រសិទ្ធភាព ។

## អនុសាសន៍

- ទោះបីគេយល់ថា ហេដ្ឋារចនាសម្ព័ន្ធ និងការបណ្តុះបណ្តាលពីការគ្រប់គ្រង លំហូរសាច់ប្រាក់មានសារៈសំខាន់បំផុត សំរាប់បង្កើនលទ្ធភាពរបស់កសិករ ដើម្បីទទួលបានសេវាហិរញ្ញវត្ថុក្តី ក៏អត្រាការប្រាក់ខ្ពស់របស់ធនាគារនៅរាំងស្ទះដំណើរការនេះដដែល ។ ដូច្នេះ ចាំបាច់ត្រូវបញ្ចុះអត្រាការប្រាក់ឱ្យនៅទាបជាង ៣% ក្នុង ១ខែ និងត្រូវផ្តល់ការគាំទ្រខាងអាជីវកម្ម ។
- កសិករកំពុងចាប់ផ្តើមពេញចិត្តនឹងគ្រាប់ពូជមានគុណភាពខ្ពស់ហើយ ប៉ុន្តែក្រោយបានថ្លឹងថ្លែងពីតម្លៃគ្រាប់ពូជទាំងនេះ កសិករភាគច្រើនក៏សំរេចចិត្តបន្តប្រើប្រាស់គ្រាប់ពូជធម្មតាដដែល ។ ដូច្នេះគួរពិចារណាផ្តល់ឧបត្ថម្ភធនជួយចេញថ្លៃឱ្យគ្រួសារកសិករក្រីក្រ ដើម្បីឱ្យពួកគេមានលទ្ធភាពទិញគ្រាប់ពូជមានគុណភាពល្អ ។
- គួរមានបង្កើតវិទ្យុសាធារណៈមួយ ដែលអាចផ្សព្វផ្សាយពីថ្លៃផលិតផលដល់គ្រប់ៗគ្នានៅក្នុងភូមិ និងគួរកែលំអសាលាម៉ាឃីទីងសំរាប់កសិករ ដើម្បីបង្កើនការចូលរៀនដោយកសិករ និងពាណិជ្ជករមូលដ្ឋាន ។
- ការស្រាវជ្រាវដោយមានការចូលរួម ត្រូវបានណែនាំឱ្យប្រើហើយ ប៉ុន្តែជាទូទៅវិធីសាស្ត្រនេះ មិនទាន់បានអនុវត្តទូលំទូលាយឡើយនៅតាមភូមិភាគច្រើន ក៏ដូចជានៅមានកង្វះខាតការតាមដានបន្ត និងការបន្តលើកទឹកចិត្ត ។ម្យ៉ាងទៀតសមត្ថភាពអ្នកផ្សព្វផ្សាយបច្ចេកទេសក៏នៅមានកំរិតដែរ ។ ដូច្នេះត្រូវពង្រឹងសមត្ថភាព អ្នកទាំងនេះ និងការជំរុញការស្រាវជ្រាវដោយមានការចូលរួមឱ្យបាន កាន់តែទូលំទូលាយ ដើម្បីបង្កើនការផ្ទេរ និងការទទួលយកបច្ចេកវិទ្យា ។
- សេវាអភិវឌ្ឍន៍ជនបទចំរុះរបស់ECOSORN ហាក់ដូចជាសក្តិសមសំរាប់តំបន់ជនបទភាគច្រើននៅកម្ពុជា ប៉ុន្តែសេវានេះមានភាពស្មុគស្មាញពិបាកគ្រប់គ្រង និងងាយនឹងរងនូវហានិភ័យ ដូចជាការអនុវត្តយឺតយូរជាដើម ។ ដូច្នេះពីដំបូងគួរដាក់បញ្ចូលសេវាតែមួយចំនួនតូច បន្ទាប់មកទើបបង្កើនចំនួនសេវាជាបន្តបន្ទាប់ ។
- ក្នុងកម្មវិធីកំណែទម្រង់កម្មសិទ្ធិដីធ្លី គួរមានបង្កើតក្របខ័ណ្ឌមួយសំរាប់អនុវត្តច្បាប់ភូមិបាលឱ្យបានឆាប់តាមអាចធ្វើបាន ដើម្បីអាចពន្លឿនដល់កម្មវិធីការប្រើប្រាស់ដីអំណោយផលដល់ជនក្រីក្រ ការចុះបញ្ជីដីធ្លី និងការធ្វើប័ណ្ណកម្មសិទ្ធិដីធ្លី ។
- ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តសាធារណៈ គួរសាងសង់ជួសជុលឱ្យបានកាន់តែច្រើន ដើម្បីជួយសម្រួលផលិតកម្ម បង្កើនពាណិជ្ជកម្មរវាងតំបន់ជនបទ និងទីក្រុង និងត្រៀមទប់ទល់នឹងគ្រោះរាំងស្ងួត និងទឹកជំនន់ ។
- គួរគិតគូរពិចារណាផ្តល់ឧបត្ថម្ភធនលើធាតុចូលដែលចាំបាច់សំរាប់កសិកម្ម ជាពិសេសនៅពេលមានវិបត្តិថ្លៃប្រេង និងជីកសិកម្ម ។

## ឯកសារយោង


Agrifood Consulting International and CamConsult (2006), Diagnostic Study, Phase 1 of Design, Agricultural Program, Cambodia, 2007–– Program Concept Document Final Report. Prepared for AusAID by Agrifood Consulting International (Bethesda, Maryland)

AMO (2008), *Agricultural Market Information Bulletin,* Monthly Report December 2008 (Agricultural Marketing Office, Ministry of Agriculture, Forestry and Fisheries) http://www.camis-kh.org/?q=en/node/79

AMO (2005), *Agricultural Market Information Bulletin,* Yearly Report 2005 (Agricultural Marketing Office, Ministry of Agriculture, Forestry and Fisheries) http://www.camis-kh.org/?q=en/node/79

Danish Agricultural Advisory Service (2008), *Mid Term Evaluation of Project KHM/AIDCO/2004/16793*—Draft Final Report (Delegation of the European Commission in Cambodia and ECOSRN in Cambodia)

Higgins, Stephen (2009), *Manufacturing and Infrastructure—Cambodia's Hidden Opportunity,* presentation to the Outlook Conference held in Phnom Penh on12 March 2009